**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសជូនដំណឹង
# របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# អំពីវិធានការហាមឃាត់ការនាំចូលជាបណ្តោះអាសន្ន
# នូវគ្រឿងក្នុង និងបំណែកសាច់បង្កក

យោងតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិត្តិយសសូមជម្រាបជូនសាធារណជន និងក្រុមហ៊ុននាំចេញ-នាំចូល មេត្តាជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្អាកជាបណ្តោះអាសន្នសម្រាប់រយៈពេល០៦(ប្រាំមួយ)ខែ នូវការនាំចូលគ្រឿងក្នុង និងបំណែកសាច់បង្កក ដែលមានលេខប្រព័ន្ធសុខដុមនីយកម្ម និងនាមវលីគយ ដូចខាងក្រោម៖

| លេខប្រព័ន្ធសុខដុមនីយកម្ម កម្ពុជា ២០២២ | បរិយាយមុខទំនិញ |
|---|---|
| ០២០៦.២១.០០ | អណ្តាត នៃសត្វគោក្របី បង្កក |
| ០២០៦.២២.០០ | ថ្លើម នៃសត្វគោក្របី បង្កក |
| ០២០៦.២៩.០០ | គ្រឿងក្នុង (Offal) បង្កកផ្សេងទៀត នៃសត្វគោក្របី ដែលអាចបរិភោគបាន ក្រៅពីអណ្តាត និងថ្លើម |
| ០២០៦.៤១.០០ | ថ្លើមនៃសត្វជ្រូក បង្កក |
| ០២០៦.៤៩.០០ | ភាគបំណែកសាច់និងគ្រឿងក្នុង (Offal) ផ្សេងទៀត ក្រៅពីថ្លើម នៃសត្វជ្រូក ដែលអាចបរិភោគបាន បង្កក |
| ០២០៧.១៤.៣០ | ថ្លើមនៃសត្វមាន់ បង្កក |
| ០២០៧.១៤.៩៩ | សាច់និងគ្រឿងក្នុង (Offal) បង្កកផ្សេងទៀត នៃសត្វមាន់ ដែលអាចបរិភោគបាន ក្រៅពីស្លាប ទាំងមូល ភ្លៅ ថ្លើម និងសាច់ដែលត្រូវបានយកឆ្អឹងចេញ (Mechanically Deboned or Separated Meat) |
| ០៥០៤.០០.០០ | ពោះវៀន ប្លោក និងក្រពះ ទាំងមូល ឬជាផ្នែក នៃសត្វ (លើកលែងត្រី) ស្រស់ ក្លាសេ្ស បង្កក ប្រឡាក់អំបិល ត្រាំទឹកអំបិល សម្ងួត ឬឆ្អើរួច |

វិធានការផ្អាកការនាំចូលជាបណ្តោះអាសន្ននេះនឹងចាប់ផ្តើមអនុវត្ត ពីថ្ងៃទី១២ ខែមីនា រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ តែវិធានការនេះមិនអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) ដែលនាំចូលទំនិញខាងលើ សម្រាប់ប្រើប្រាស់ជាធាតុចូលផលិតកម្មសម្រាប់ការនាំចេញ ឡើយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងក្រុមហ៊ុននាំចេញ-នាំចូល ដែលកំពុងប្រកបអាជីវកម្មលើមុខទំនិញខាងលើ ព្រមទាំងភាគីពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មាន។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងមក ៖

**១. ក្រសួងពាណិជ្ជកម្ម តាមរយៈ**

-ទូរសព្ទលេខ៖ ០១២ ៣៨៧ ៨៧៨ ឬ

-អ៊ីម៉ែល៖ kim.meassokseiha@moc.gov.kh

**២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈ**

-ទូរសព្ទលេខ៖ ០១៧ ៤០៨ ៨៨៨ ឬ

-អ៊ីម៉ែល៖ Info@maff.gov.kh

ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមថា សាធារណជន ក្រុមហ៊ុននាំចេញ-នាំចូល និងភាគីពាក់ព័ន្ធ នឹងចូលរួមសហការអនុវត្តវិធានការនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤

**ក្រសួងពាណិជ្ជកម្ម** **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**